**NEWS RELEASE**

UNITED NATIONS
HUMAN RIGHTS
SPECIAL PROCEDURES
SPECIAL RAPPORTEURS, INDEPENDENT EXPERTS & WORKING GROUPS

# កម្ពុជា៖ អ្នកជំនាញ អ.ស.ប មានកង្វល់ចំពោះសកម្មភាពរបស់រដ្ឋាភិបាលក្នុងការបំបិទសំឡេងដៃគូប្រជែងនយោបាយ

ទីក្រុងហ្សឺណែវ (១៩ មិថុនា ២០១៩) អ្នកជំនាញ*សិទ្ធិមនុស្សអង្គការសហប្រជាជាតិបានសម្តែងកង្វល់ចំពោះនិន្នាការកើនឡើងនៃការគាបសង្កត់ដោយរដ្ឋាភិបាលកម្ពុជាទៅលើមតិយោបល់ផ្ទុយពីខ្លួនដែលហាក់ដូចជាមានបំណងបំភិតបំភ័យ ឬបំបិទគំនិតនយោបាយ។

យោងតាមព័ត៌មានដែលទទួលបាន សមាជិកអតីតគណៈបក្សសង្គ្រោះជាតិ (CNRP) ជាង ១៤០ រូប ត្រូវបានអាជ្ញាធរចោទសួរ កោះហៅ ឬឃុំខ្លួន ពាក់ព័ន្ធនឹងការចូលរួមក្នុងការប្រមូលផ្តុំ និងការអត្ថាធិប្បាយគាំទ្រអតីតមេដឹកនាំទាំងពីររូបគឺ លោក កឹម សុខា និង លោក សម រង្ស៊ីនៃគណបក្សសង្គ្រោះជាតិដែលត្រូវបានតុលាការរំលាយហើយនោះ។ បុគ្គលមួយចំនួនខាងលើនោះបានបង្ហោះវីដេអូអំពីការប្រមូលផ្តុំ និងសេចក្តីថ្លែងការណ៍គាំទ្រ លោក កឹម សុខា និងលោក សម រង្ស៊ី តាមហ្វេសប៊ុក។

ក្រុមអ្នកជំនាញបានមានប្រសាសន៍ថា "យើងមានកង្វល់អំពីការប្រើច្បាប់ព្រហ្មទណ្ឌ ដើម្បីដាក់គោលដៅទៅលើ ការនិយាយស្តីដោយសេរី ទាំងតាមអូហ្វឡាញ ទាំងតាមអនឡាញ"។ "មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះគឺជាមូលដ្ឋានគ្រឹះសម្រាប់សង្គមមួយបែបប្រជាធិបតេយ្យ និងយុត្តិធម៌។ ការរឹតត្បិតលើសេរីភាពក្នុងការបញ្ចេញមតិ ត្រូវតែមានដែនកំណត់ និងត្រូវបានកំណត់ន័យឲ្យបានច្បាស់លាស់ ហើយសេចក្តីថ្លែងការណ៍គាំទ្រដល់អ្នកដឹកនាំនយោបាយ មិនស្ថិតក្នុងដែនកំណត់ដែលអនុញ្ញាតនោះឡើយ។

ក្រុមអ្នកជំនាញបានមានប្រសាសន៍ថា ការរឹតត្បិតណាមួយលើសេរីភាពបញ្ចេញមតិ ឬសេរីភាពក្នុងការជួបប្រជុំ ត្រូវតែបានកំណត់តាមនិយមន័យចង្អៀត។ ការរឹតត្បិតត្រូវតែផ្អែកលើអ្វីដែលមានចែងក្នុងច្បាប់ ដែលចាំបាច់ដើម្បីគាំទ្រដល់ហេតុផលស្របច្បាប់ ដូចជា ការការពារសណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិ ហើយការរឹតត្បិតទាំងនោះ ត្រូវតែមានសមាមាត្រ ដើម្បីឆ្លើយតបទៅនឹងគោលបំណងដែលប្រាថ្នាចង់បាន។ ការចោទប្រកាន់ពី "បទញុះញង់ឲ្យប្រព្រឹត្តបទល្មើស" ដែលអាជ្ញាធរបានចោទប្រកាន់ជាសាធារណៈលើបុគ្គលមួយចំនួន មិនមែនជាការរឹតត្បិតសមស្របទៅលើការសម្តែងមតិគាំទ្រដល់ឥស្សរជននយោបាយឡើយ។

ក្រុមអ្នកជំនាញក៏បានសម្តែងកង្វល់ផងដែរថា ដីកាដែលកោះបុគ្គលជាច្រើនខាងលើ ទំនងជាផ្ទុយនឹងគោលការណ៍ស្តីពីសិទ្ធិទទួលបានដំណើរការត្រឹមត្រូវ និងការជំនុំជម្រះប្រកបដោយយុត្តិធម៌ ជាពិសេសគោលការណ៍សិទ្ធិស្មើគ្នា និងសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់សម្រាប់ការរៀបចំការពារខ្លួនរបស់គេ រាប់ទាំង សិទ្ធិទទួលបានព័ត៌មានសមស្របផងដែរ។

ក្រុមអ្នកជំនាញបានមានប្រសាសន៍ថា ដីកាដែលបានកោះអតីតសមាជិកជាច្រើនរូបរបស់គណបក្សសង្គ្រោះជាតិ បានយោងទៅលើការចោទប្រកាន់ពីការរំលោភលើសាលដីការបស់តុលាការកំពូលស្តីពីការរំលាយគណបក្សសង្គ្រោះជាតិ ចាប់ពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ មក ដោយមិនបានបញ្ជាក់ច្បាស់ពីលក្ខណៈនៃការរំលោភបំពានដែលបានចោទនោះទេ។ ក្រុមអ្នកជំនាញបានមានប្រសាសន៍បន្ថែមថា មេធាវីការពារក្តីមិនត្រូវបានអនុញ្ញាតឲ្យធ្វើការថតចម្លងឯកសារណាមួយនៅក្នុងសំណុំរឿង ដើម្បីរៀបចំការពារឲ្យបានគ្រប់គ្រាន់ទាន់ពេលវេលានោះឡើយ។

នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ តុលាការកំពូលបានរំលាយគណបក្សសង្គ្រោះជាតិ ដែលជាគណបក្សប្រឆាំងដ៏ធំមួយ និងជាគណបក្សប្រឆាំងតែមួយគត់ដែលមានអសនៈនៅក្នុងរដ្ឋសភា ដែលធ្វើឲ្យកម្ពុជាក្លាយជារដ្ឋឯកបក្ស ក្រោមការគ្រប់គ្រងរបស់គណបក្សប្រជាជនកម្ពុជា (CPP) ពិតឥតប្រកែកបាន។

ក្រុមអ្នកជំនាញបានមានប្រសាសន៍ថា "យើងសូមអំពាវនាវដល់រដ្ឋាភិបាល ឲ្យស្តារនិន្នាការធ្លាក់ចុះបច្ចុប្បន្នក្នុងការទទួលបានសិទ្ធិនយោបាយ និងសេរីភាពជាមូលដ្ឋាន"។ "ដល់ពេលដែលរដ្ឋាភិបាលដឹកនាំឲ្យផ្លាស់ប្តូរវប្បធម៌នយោបាយទៅជាកិច្ចសន្ទនាមួយ ដែលផ្តោតទៅលើបញ្ហាជាជាងផ្តោតលើបុគ្គលដែលវាជាវិធីមួយឈានទៅមុខ និងបង្កើតមូលដ្ឋានរឹងមាំសម្រាប់សន្តិភាពយូរអង្វែង ការអភិវឌ្ឍន៍កបដោយចីរភាព និងការទទួលបានសិទ្ធិមនុស្សទាំងអស់"។

**ចប់**

*(*)* ***អ្នកជំនាញ អ.ស.ប៖ លោកស្រី សាស្ត្រាចារ្យ រ៉ូណា ស្មីត*** *(ចក្រភពអង់គ្លេស) អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោក* ***ដាវីដ កាយេ*** *អ្នករាយការណ៍ពិសេសស្តីពីការលើកស្ទួយ និងការពារសិទ្ធិសេរីភាពនៃគំនិត និងការបញ្ចេញមតិ។*

*អ្នករាយការណ៍ពិសេស ពួកគាត់គឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយនៃអ្នកជំនាញឯករាជ្យនៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅមួយនៃយន្តការឃ្លាំមើល និងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ។ អ្នកកាន់អាណត្តិនីតិវិធីពិសេស គឺជាអ្នកជំនាញ ឯករាជ្យ ដែលក្រុមប្រឹក្សាសិទ្ធិមនុស្សបានតែងតាំងឡើង ដើម្បីធ្វើការងារពាក់ព័ន្ធនឹងស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសមួយជាក់លាក់ ឬបញ្ហាសិទ្ធិមនុស្សតាមវិស័យ*

នីមួយៗ នៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយធ្វើការឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ។ ពួកគាត់បម្រើការក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ ខ្លួន ហើយមិនទទួលប្រាក់បៀវត្សរ៍លើការងារនេះឡើយ។

ពិនិត្យមើលរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្ដីពីប្រទេសកម្ពុជា និង មើលទំព័រហ្វេសប៊ុករបស់អ្នករាយការណ៍ពិសេស
https://www.facebook.com/SpecialRapporteurCambodia/?modal=admin_todo_tour សិទ្ធិមនុស្ស អ.ស.ប ទំព័រប្រទេស៖ ប្រទេសកម្ពុជា

សម្រាប់ព័ត៌មានបន្ថែម និងការសាកសួរព័ត៌មានផ្សេងៗ សូមទាក់ទង៖
លោកស្រី អ៊ីស្ទើរ ឡាំ (Esther Lam) តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩២៨ ៩១ ០៨ ឬ អ៊ីម៉ែល elam@ohchr.org ម៉ាសម៉ូដ ហ្គារហ្គា តាមរយៈទូរស័ព្ទ៖ (+៨៥៥ (0)១២ ៧៩០ ១៧៨ អ៊ីម៉ែល mgarga@ohchr.org)

សម្រាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមទាក់ទង៖
លោក ហ្សេរ៉ឺមី ឡូរង់ស៍ (Jeremy Laurence) សិទ្ធិមនុស្ស អ.ស.ប– អង្គភាពប្រព័ន្ធផ្សព្វផ្សាយ តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩១៧ ៩៣៨៣ ឬ អ៊ីម៉ែល jlaurence@ohchr.org)